**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៤០៣ សហវ.ឯក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០១១

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ចំនួន ៤ ១៨៥ ៧៨៥ ៥៦៣ រៀល ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ជួសជុលប្រព័ន្ធស្រោចស្រព ទំនប់អាងទឹកអូរខ្លុង ស្ថិតនៅឃុំស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ០៤២ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្ដល់ជានាចំណាយត្រឹមចំនួន ៤ ០៥៤ ០០០ ០០០ រៀល(បួនពាន់ហាសិបបួនលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ជួសជុលប្រព័ន្ធស្រោចស្រពទំនប់អាងទឹកអូរខ្លុង ស្ថិតនៅឃុំស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង រួមមាន៖

| | |
|---|---|
| - ជួសជុលទំនប់អូរខ្លុង | ប្រវែង ៩៥៥ ម៉ែត្រ |
| - ស្ដារប្រឡាយមេ ១ខ្សែ | ប្រវែង ៤.៨៥០ម៉ែត្រ |
| - សាងសង់សំណង់លូជ្រុងបញ្ចេញទឹក ទ្វារ ១ លើទំនប់អូរខ្លុង | ចំនួន ២កន្លែង |
| - សាងសង់សំណង់បង្ហៀរ ទ្វារ ១ លើទំនប់អូរខ្លុង | ចំនួន ២កន្លែង |
| - សាងសង់សំណង់ប្រឡាយ បេតុង លើទំនប់អូរខ្លុង | ប្រវែង ១០០ម៉ែត្រ |
| - សាងសង់សំណង់លូមូលឆ្លងផ្លូវ ទ្វារ ១ លើប្រឡាយមេខ្សែទី១ | ចំនួន ១កន្លែង |
| - សាងសង់សំណង់លូមូល ទ្វារ ១ លើប្រឡាយមេខ្សែទី១ | ចំនួន ១កន្លែង |
| - សាងសង់សំណង់ស្ទាក់ទឹក លើប្រឡាយមេខ្សែទី១ | ចំនួន ១កន្លែង |

សេចក្ដីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តស្ទឹងត្រែង
- នាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្ទឹងត្រែង
- ឯកសារ-កាលប្បវត្តិ